**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ..៨៣...អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៧ មាត្រា៨ និងមាត្រា២៥**
**នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩**
**ស្តីពីការកំណត់របបជីវភាពសម្រាប់ពិរុទ្ធជន និងទណ្ឌិត**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការកំណត់របបជីវភាពសម្រាប់ពិរុទ្ធជន និងទណ្ឌិត
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៩ មាត្រា១០ មាត្រា៤២ និងមាត្រា៤៥ នៃអនុក្រឹត្យលេខ១០៩អនក្រ.បក ចុះថ្ងៃ ទី១៩ ខែសីហា ឆ្នាំ២០១៥ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រាមួយ.-**

ត្រូវបានកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៧ មាត្រា៨ និងមាត្រា២៥ នៃអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការកំណត់របបជីវភាពសម្រាប់ពិរុទ្ធជន និងទណ្ឌិត ដូចខាងក្រោមៈ

**មាត្រា៣ ថ្មី.-**

ពាក្យ"ពិរុទ្ធជននិងទណ្ឌិត"ដែលប្រើក្នុងអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការកំណត់របបជីវភាពសម្រាប់ពិរុទ្ធជននិងទណ្ឌិតត្រូវបានជំនួសដោយពាក្យ ជនជាប់ឃុំ។

**មាត្រា៥ ថ្មី.-**

កូនរបស់ជនជាប់ឃុំមានអាយុក្រោម៣ឆ្នាំ ដែលពុំអាចបំបែកចេញពីម្ដាយ ត្រូវបានទទួលរបបជីវភាពដែលកំណត់ដោយអនុក្រឹត្យនេះ។

**មាត្រា៧ ថ្មី.-**

ជនជាប់ឃុំម្នាក់ៗ ត្រូវទទួលបានរបបហូបចុកប្រចាំថ្ងៃចំនួន ៣ ៥០០រៀល។ ចំពោះជនជាប់ឃុំដែលបានចាប់ក្នុងខែ ហើយមិនទាន់បានស្នើសុំរបបហូបចុកប្រចាំថ្ងៃត្រូវបានរំលឹកជូននៅក្នុងខែបន្ទាប់។

**មាត្រា៨ ថ្មី.-**

កូនមួយនាក់របស់ជនជាប់ឃុំ រស់នៅជាមួយម្ដាយក្នុងពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែ ដែលមានអាយុក្រោម៣ឆ្នាំ ត្រូវបានទទួលរបបហូបចុកស្មើនឹងពាក់កណ្ដាលនៃរបបជនជាប់ឃុំមួយនាក់។

**មាត្រា២៥ ថ្មី.-**

នៅពេលត្រូវបានដោះលែងចេញពីពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែ ទណ្ឌិតម្នាក់ ត្រូវបានទទួលខោអាវថ្មីមួយសម្រាប់ស្មើនឹងប្រាក់ ៥០ ០០០រៀល និងប្រាក់ឧបត្ថម្ភចំនួន ១០០ ០០០រៀល សម្រាប់ធ្វើដំណើរ ហូបចុកតាមផ្លូវ។

**មាត្រាពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រាបី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩តទៅ។

ថ្ងៃសុក្រ ១០កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ